# ឯកឧត្តមទេស រដ្ឋមន្ត្រី ចម ប្រសិទ្ធ ក្រើនរំឭកមន្ត្រីក្រោមឱវាទ ឲ្យបន្ត ផ្លុះកញ្ចក់ង្វតទឹក ដុះក្អែល ដើម្បីប្រសិទ្ធភាពការងារកាន់តែប្រសើរ



**(ភ្នំពេញ)៖** ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំកិច្ចប្រជុំអឌ្ឍមាសរបស់ខ្លួន នៅសាលប្រជុំនៃរដ្ឋាករទឹកភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួង នៅព្រឹកថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ នេះ។

កិច្ចប្រជុំត្រូវបានរៀបចំឡើង ក្រោមរបៀវារៈ ៤ ក្នុងនោះរួមមាន ទី១-ការប្រកាសតែងតាំងមុខតំណែងថ្មីដល់មន្ត្រីរាជការក្រសួងឧស្សាហកម្ម និងសិប្បកម្មចំនួន ១៤រូប ។ ទី២ ការកែសម្រួលភារកិច្ចថ្នាក់ដឹកនាំ ទទួលបន្ទុកលើកិច្ចការរបស់នាយកដ្ឋាននីមួយៗ និងមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត។ ទី៣-ការប្រកាសពីលទ្ធផល នៃការបោះឆ្នោត

សម្ងាត់ស្ទាបស្ទង់ មតិវាយតម្លៃពីភ្នែកមហាជន។ ទី៤,ការត្រៀមរៀបចំពិធីសម្ពោធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅទីរួមខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែននិង ទី៥-របាយការណ៍វឌ្ឍនភាព នៃការងាររបស់អគ្គនាយកដ្ឋាននីមួយៗ ។

គួររំឭកផងដែរថា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំឲ្យមានការបោះឆ្នោតជាសម្ងាត់ ក្នុងចំណោមមន្ត្រីរាជការទាំងអស់នៅក្នុងក្រសួង ដើម្បីធ្វើការវាយតម្លៃលើការងារដឹកនាំ គ្រប់គ្រង និងការងារបច្ចេកទេស របស់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់រូបនៅក្នុងក្រសួង។ ការបោះឆ្នោតនេះ បានផ្តល់ឱកាសឲ្យមន្ត្រីរាជការ នៅតាមនាយកដ្ឋាននីមួយៗ អាចបញ្ចេញមតិជាសម្ងាត់ និងយុត្តិធម៌ តាមរយៈសន្លឹកឆ្នោតរបស់ខ្លួន ទៅលើអត្តចរិក សីលធម៌ និងការងារដឹកនាំ គ្រប់គ្រងរបស់មេកើយ និងមន្ត្រីនានានៅតាមអង្គភាពរបស់ខ្លួន។ លទ្ធផលនៃការបោះឆ្នោតនេះ បានបង្ហាញឲ្យឃើញពីពិន្ទុ វាយតម្លៃលើការងារដឹកនាំ គ្រប់គ្រងរបស់ថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងថ្នាក់ដឹកនាំនាយកដ្ឋាន ថាតើបុគ្គលរូបណាមានការពេញចិត្ត និងបុគ្គលរូបណាមានការមិនពេញចិត្ត ពីសំណាក់មន្ត្រីក្រោមឱវាទរបស់ខ្លួន។

តាមលទ្ធផលនៃការបោះឆ្នោត បានបង្ហាញឲ្យឃើញថា ថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំនាយកដ្ឋាន មួយចំនួនធំបានទទួលការពេញចិត្តពីមន្ត្រីក្រោមឱវាទរបស់ខ្លួន។ ដោយឡែកក៏មានថ្នាក់ដឹកនាំ របស់នាយកដ្ឋានមួយចំនួនតូច ទទួលបានការមិនពេញពីមន្ត្រីក្រោមឱវាទរបស់ខ្លួនផងដែរ។

ថ្លែងក្នុងឱកាសនេះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានកោតសរសើរ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីដែលទទួលបានការពេញចិត្តច្រើន ហើយស្នើឲ្យបន្តការងាររបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។ ជាមួយគ្នានេះ លោកក៏បានដាស់តឿន និងក្រើនរំឭកចំពោះមន្ត្រីដែលទទួលបានការមិនពេញចិត្តច្រើន ត្រូវឆ្លុះកញ្ចក់ ងូតទឹក និងដុះក្អែល ព្រមទាំងធ្វើការប្រែឡើងវិញទាំងអត្តចរិក និងការងារគ្រប់គ្រងដឹកនាំ ជៀសវាងការថ្នាំងថ្នាក់ពីមន្ត្រីថ្នាក់ក្រោម ដែលអាចឈានទៅដល់ការរះកាត់ណាមួយ នៅថ្ងៃអនាគត។ ការបោះឆ្នោតស្ទាបស្ទង់មតិនេះ នឹងត្រូវធ្វើឡើងរៀងរាល់១ឆមាសម្តង។

ការបោះឆ្នោតនេះ បានបង្ហាញឲ្យឃើញពីការប្តេជ្ញាចិត្ត និងការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវអនុសាសន៍របស់ប្រមុខដឹកនាំរាជរដ្ឋាភិបាល សម្តេចតេជោ ហ៊ុន សែន ក្នុងគោលការណ៍

ឆ្លុះកញ្ចក់ ងូតទឹក ដុះក្អែល និងវះកាត់ សម្រាប់មន្ត្រីរាជការទាំងអស់អនុត្ត ហើយក៏ជាការដាស់ស្មារតីមួយដល់មន្ត្រីរាជការគ្រប់រូប ឲ្យបំពេញការងាររបស់ខ្លួន ប្រកប ដោយក្រមសីលធម៌ វិជ្ជាជីវៈ ដោយការទទួលខុសត្រូវ និងប្រកបដោយប្រសិទ្ធភាពខ្ពស់៕



